# គ្រួសារថ្មី៖ បង្កើតគណនី ParentVUE និងចុះឈ្មោះសិស្សរបស់អ្នក

ប្រើប្រាស់ ParentVUE ប្រព័ន្ធផតថលតាមអនឡាញរបស់យើងសម្រាប់គ្រួសារ ដើម្បីចុះឈ្មោះសិស្សថ្មី។ នៅពេលដែលបានចុះឈ្មោះរួច ParentVUE អនុញ្ញាតឱ្យអ្នកពិនិត្យមើលអំពីវត្តមាន ចំណាត់ថ្នាក់ កាលវិភាគ ឯកសារ និងរាយការណ៍ពីអវត្តមានសិស្សរបស់អ្នក។

**ស្កេនខ្ញុំដើម្បីស្វែងយល់បន្ថែម!**

**គន្លឹះសំខាន់! យើងណែនាំឱ្យប្រើប្រាស់កម្មវិធីនេះនៅលើកុំព្យូទ័រយួរដៃ ឬកុំព្យូទ័រលើតុ។**




## ជំហានទី 1

ចូលទៅកាន់ tacomaschools.org/enroll

- សូមពិនិត្យមើលអ្នករស់នៅក្នុងតំបន់ព្រំប្រទល់
- របស់យើង ប្រមូលឯកសារដែលអ្នកនឹងត្រូវការ
- ដើម្បីចុះឈ្មោះ សូមចុចប៊ូតុង “ចុះឈ្មោះសិស្សថ្មី” ដើម្បីចូលទៅកាន់ ParentVUE។




## ជំហានទី 2

សូមចុចប៊ូតុងពណ៌លឿង “បង្កើតគណនីថ្មី”។

## ជំហានទី 3

ឆ្លើយសំណួរវាយតម្លៃ ហើយចុចបន្ត។ អាន និងទទួលយកសេចក្ដីថ្លែងការណ៍ឯកជនភាព។




## ជំហានទី 4

បញ្ចូលព័ត៌មានរបស់អ្នកក្នុងនាមចុះឈ្មោះជាឪពុកម្ដាយ/អាណាព្យាបាល ហើយចុចបន្ត ទៅកាន់ជំហានទី 3។

## ជំហានទី 5

អ្នកនឹងទទួលបានការបញ្ជាក់ និងការណែនាំដើម្បីពិនិត្យមើលអ៊ីមែលរបស់អ្នក ក្នុងការបញ្ចប់ការបង្កើតគណនីរបស់អ្នក។

ការណែនាំបន្ត

TACOMA PUBLIC SCHOOLS

ParentVUE® powered by Synergy®

# គ្រួសារថ្មី៖ បង្កើតគណនី ParentVUE និងចុះឈ្មោះសិស្សរបស់អ្នក

## ជំហានទី 6

ពិនិត្យមើលអ៊ីមែលរបស់អ្នក និងស្វែងរកសារពី Synergy Mail noreply@tacoma.k12.wa.us។ សូមចុចកន្លែងដែលបានណែនាំនៅក្នុងអ៊ីមែលដើម្បីបន្ត។




## ជំហានទី 7

ដើម្បីបំពេញគណនីរបស់អ្នក សូមបង្កើតលេខកូដសម្ងាត់ ហើយចុចរក្សាទុក និងបន្ត

## ជំហានទី 8

បន្ទាប់ពីការបង្កើតគណនីរបស់អ្នក ឥឡូវនេះ អ្នកអាចចាប់ផ្តើមការចុះបញ្ជីចុះឈ្មោះរបស់អ្នកបានហើយ។ សូមចុច ចាប់ផ្តើមការចុះឈ្មោះថ្មី។




## ជំហានទី 9

បំពេញផ្នែកនីមួយៗដើម្បីពិនិត្យមើល និងបញ្ជូនការចុះឈ្មោះសិស្សរបស់អ្នក។

- សេចក្តីផ្តើម
- គ្រួសារ
- ឪពុកម្តាយ/ អាណាព្យាបាល
- គ្រាអាសន្ន
- សិស្ស
- ពិនិត្យមើល/ បញ្ជូន




## ជំហានទី 10

បន្ទាប់ពីបញ្ជូន អ្នកអាចពិនិត្យមើលពីស្ថានភាព ដោយចុចលើស្ថានភាព (Status) ពេលដែលអ្នកត្រឡប់ទៅ ParentVUE វិញ។

## ជំហានទី 11

នៅពេលដែលការចុះឈ្មោះត្រូវបានអនុម័ត អ្នកនឹងទទួលបានអ៊ីមែលមួយ។




TACOMA PUBLIC SCHOOLS

ParentVUE® powered by Synergy®